ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥

**សូមគោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំអនុវត្ត**ជំហានទី១** ក្នុងការភ្ជាប់ចរន្ត ៦១០ រៀល ជូនកម្មករ កម្មការនី ដែលជួលផ្ទះ ឬបន្ទប់ក្នុងតំបន់ចែកចាយផ្ទាល់របស់អគ្គិសនីកម្ពុជានៅរាជធានីភ្នំពេញ។

**យោង** ៖ -លិខិតលេខ០៤៩១ បោ.អក.លខ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ របស់អគ្គិសនីកម្ពុជា។

-លិខិតលេខ០៤៩២ អក.លខ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ របស់អគ្គិសនីកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមអភិបាលមេត្តាជ្រាបថា ដោយប្រើប្រាស់ធនធានមនុស្ស និងសម្ភារក្នុងឃ្លាំងដែលមានស្រាប់របស់អគ្គិសនីកម្ពុជា និងដើម្បីជម្រុញឲ្យយន្តការថ្លៃអគ្គិសនី ៦១០រៀល ឆាប់បានដល់ដៃប្រជាពលរដ្ឋដែលស្នាក់នៅផ្ទះជួល ឬ បន្ទប់ជួល យើងខ្ញុំសូមស្នើសុំឲ្យឯកឧត្តមអភិបាលមេត្តាជួយសហការអនុវត្តកម្មវិធីការងារ**ជំហានទី១**។ គោលការណ៍រួមគឺយកតំបន់ប្រមូលផ្តុំដែលមានអ្នកជួលផ្ទះ ឬ ជួលបន្ទប់នៅផ្តុំគ្នាច្រើនជាអាទិភាពខ្ពស់។

ក្នុង**ជំហានទី១** នេះនឹងចាប់ផ្តើមនៅថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០១៥ តទៅ។ យើងខ្ញុំសូមបែងចែកការងារដូចខាងក្រោម៖

១.ខណ្ឌឬស្សីកែវ ៖ នៅសង្កាត់ទួលសង្កែ ដែលមានក្រុមនិយោជិតរបស់អគ្គិសនីកម្ពុជាចំនួន ១០ ក្រុម មានចំនួនសរុប ៨០ នាក់ ។

២.ខណ្ឌមានជ័យ ៖ នៅសង្កាត់ចាក់អង្រែលើ និងសង្កាត់ចាក់អង្រែក្រោម ដែលមានក្រុមនិយោជិតរបស់អគ្គិសនីកម្ពុជា ចំនួន ១០ ក្រុម មានចំនួនសរុប ៨០ នាក់ ។

៣.ខណ្ឌដង្កោ ៖ នៅសង្កាត់ដង្កោ ដែលមានក្រុមនិយោជិតរបស់អគ្គិសនីកម្ពុជា ចំនួន ១០ ក្រុម មានចំនួនសរុប ៨០ នាក់ ។

ក្រុមនិយោជិតរបស់អគ្គិសនីកម្ពុជា នឹងចុះទៅទទួលពាក្យស្នើសុំបន្តចរន្ត និងធ្វើការតភ្ជាប់ចរន្តអគ្គិសនីនៅទីតាំងស្នាក់នៅរបស់កម្មករ កម្មការី។ ចំនួនក្រុមការងារនេះ មិនរាប់បញ្ចូលក្រុមការងារដោយឡែករបស់អគ្គិសនីកម្ពុជាក្នុងការចុះទៅវាយតម្លៃសំណង់ថ្លៃខ្សែ និងឧបករណ៍អគ្គិសនីត្រឹមប្រអប់នាឡិកាស្ទង់របស់ម្ចាស់ផ្ទះជួល ឬបន្ទប់ជួលទេ។ ក្រុមការងារខាងលើត្រូវធ្វើការជាមួយអ្នកជួលផ្ទះ ឬ ជួលបន្ទប់ ចាប់ពីថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ ២០១៥ ពីម៉ោង ៤: ៣០ ល្ងាច ដល់ម៉ោង ០៨: ៣០យប់ សម្រាប់ពីថ្ងៃ ច័ន្ទ- សៅរ៍ និង ពីម៉ោង ០៨: ០០ព្រឹក ដល់ម៉ោង ០៥: ០០ល្ងាច សម្រាប់ថ្ងៃអាទិត្យ។ ខ្ញុំបាទសូមសំណូមពរស្នើសុំកងកំលាំងប្រដាប់អាវុធចំនួន១នាក់សម្រាប់អមក្រុមការងារនិមួយៗរៀងរាល់ម៉ោងបំពេញភារកិច្ច។ ក្រុមការងារនេះនឹងជួបប្រជុំគ្នាមុនចេញទៅបំពេញការងារនៅសាលាសង្កាត់និមួយៗ។

ចាប់ពីថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០១៥ នេះដែរ នៅរៀងរាល់ថ្ងៃ ពេលព្រឹក ពីម៉ោង ៨៖៣០ នាទីដល់ម៉ោង ១២៖០០នាទី និងពេលរសៀលពីម៉ោង ២៖៣០នាទី ដល់ម៉ោង៤៖០០នាទីក្នុងមួយខណ្ឌមាន ៤

អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២៣ ៨៧១ - ៧២៤ ៧៧១ ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨

ក្រុមការងារ ដើម្បីចុះទៅជួបជាមួយម្ចាស់ដី ឬ ម្ចាស់ផ្ទះ ឬ ម្ចាស់បន្ទប់ ដើម្បីធ្វើការវាយតម្លៃសំណង។ ខ្ញុំបាទសូមសំណូមពរស្នើសុំមន្ត្រីខណ្ឌ/សង្កាត់ផ្នែករដ្ឋបាល ចំនួន៤នាក់ ដើម្បីចូលរួមក្នុងការងារនេះ។ ក្រុមការងារនេះនឹងជួបប្រជុំគ្នានៅសាលាសង្កាត់ដែរ។

អាស្រ័យទៅលើវឌ្ឍនភាពនៃ**ជំហានទី១**នេះ ការប្រកាសជំហានទី២នឹងត្រូវបានស្នើសុំបន្តតាមជាក់ស្តែង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាល មេត្តាជ្រាបជាព័ត៌មាន និងពិនិត្យលទ្ធភាពផ្តល់ការសហការយ៉ាងពេញលេញដោយក្តីអនុគ្រោះ។

សូមឯកឧត្តមអភិបាល មេត្តាទទួលនូវគារវកិច្ច និងការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

**ចម្លងជូន**

- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល
- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តមប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា
- ឯកឧត្តម ឃួង ស្រេង អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ
- ឯកសារ កាលប្បវត្តិ